※本文の複製、転載、改変、再配布を禁止します。

សំនួរនៅប្រទេសកម្ពុជា

<សំនួរសំរាប់ការិយាល័យ>

## 【1】សំនួរពាក់ព័ន្ធនឹងសិទ្ធិដាក់ពាក្យ

## I. អំពីនីតិវិធី

**1.**

អំពីហត្ថលេខាក្នុងលិខិតប្រគល់សិទ្ធិដល់ភ្នាក់ងារ ដែលត្រូវថែងនៅក្នុងប្រការ៣៣នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ តើតំរូវអោយបញ្ជាក់ពីសិទ្ធិអំណាច និងធ្វើនៅមន្ទីរសារការីលើហត្ថលេខាដែររឺទេ? ក្នុងករណីតំរូវ តើចាំបាច់មាន ①លិខិតបញ្ជាក់ពីមុខងារ ②ការបញ្ជាក់ទទួលស្គាល់លើហត្ថលេខាដោយសារការី(ជប៉ុន) ③ការបញ្ជាក់ទទួលស្គាល់របស់កុងស៊ុលលើលិខិតខាងលើដែររឺទេ? ក្នុងករណីចាំបាច់ធ្វើនៅមន្ទីរសារការី តើអនុញ្ញាតអោយធ្វើការបញ្ជាក់ដោយអ្នកដំណាងដែលយោងតាមច្បាប់នៅប្រទេសជប៉ុនបានរឺអត់? ត្រូវទាមទារនូវការបញ្ជាក់នៅចំពោះមុខ?

**2.**

ចំពោះការចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិពីតក្កករដល់អ្នកដាក់ពាក្យសុំ

※本文の複製、転載、改変、再配布を禁止します。

ដែលចែងនៅក្នុងមាត្រា១៧នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរខស្សាហកម្ម និងប្រការ៦（Rule6）

នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

តើគេទាមទារបញ្ជាក់ពីសិទ្ធិអំណាចនិងធ្វើនៅមន្ទីរសារការីលើហត្ថលេខាដែររឺទេ?

ក្នុងករណីមានការទាមទារថាតើត្រូវការ ①លិខិតបញ្ជាក់ពីមុខងាររបស់ហត្ថលេខី ②

ការបញ្ជាក់ទទួលស្គាល់លើហត្ថលេខាដោយសារការី(ជប៉ុន) ③

ការបញ្ជាក់ទទួលស្គាល់របស់កុងស៊ុលលើលិខិតខាងលើដែររឺទេ?

ក្នុងករណីចាំបាច់ធ្វើនៅមន្ទីរសារការី

តើអនុញ្ញាតអោយធ្វើការបញ្ជាក់ដោយអ្នកដំណាងដែលយោងតាមច្បាប់នៅប្រទេសជប៉ុនបានរឺអត់? ត្រូវទាមទារនូវការបញ្ជាក់នៅចំពោះមុខ?

ម្យ៉ាងទៀតថាតើខ្លឹមសារអ្វីខ្លះដែលចាំបាច់នៅក្នុងលិខិតផ្ទេរសិទ្ធិ(ឯកសារនៅប្រការទី២មាត្រា១៧នៃច្បាប់)នោះ។

**3.**

ក្នុងករណីតក្កកម្មក្នុងករណីយកិច្ចទៅតាមកិច្ចសន្យាការងារ

សិទ្ធិដែលទទួលប្រកាសនីយបត្រតក្កកម្មគឺខាងនិយោជិក។

ចុះថាតើចាំបាច់មានលិខិតផ្ទេរសិទ្ធិពីតក្កករដែររឺទេ?

**4.**

※本文の複製、転載、改変、再配布を禁止します。

លិខិតបញ្ជាក់ស្តីពីអាទិភាព

ដែលត្រូវចែងនៅក្នុងមាត្រា២៨នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមាន

អត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម និងប្រការទី២០ ( Rule20 )

នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍នោះ

ថាតើដាក់តែក្នុងករណីមន្ត្រីកាន់កាប់បញ្ជីបានទាមទារតែប៉ុណ្ណោះទេ?

ម្យ៉ាងទៀតថាតើករណីយ៉ាងដូចម្តេច

បានជាមន្ត្រីកាន់កាប់បញ្ជីទាមទារលិខិតបញ្ជាក់ស្តីពីអាទិភាពនោះ?

**5.**

យោងតាមប្រការទី២០ ( Rule20 ) នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

លិខិតបញ្ជាក់ស្តីពីអាទិភាពក្រៅពីភាសាខ្មែរទាំងអស់ចាំបាច់ដាក់ឯកសារបកប្រែទាំងស្រុងមែន

ទេ? អាចទទួលស្គាល់ពីការបកប្រែមួយផ្នែកដែររឺទេ?

ម្យ៉ាងទៀតក្នុងករណីមានលិខិតបញ្ជាក់ស្តីពីអាទិភាពជាភាសាអង់គ្លេសរឺមានឯកសារបកប្រែភា

សាអង់គ្លេសរួចហើយ ក៏ចាំបាច់បកប្រែជាភាសាខ្មែរដែររឺទេ?

ហើយនឹងថាតើអាចទទួលស្គាល់ពីពន្យាពេលនៃការដាក់លិខិតបញ្ជាក់ស្តីពីអាទិភាពដែររឺទេ?

**6.**

※本文の複製、転載、改変、再配布を禁止します。

ក្នុងករណីដាក់លិខិតជាក្រៅពីភាសាខ្មែរ ថាតើអាចទុកពេលវេលាអាចធានាកាលបរិច្ឆេទដាក់ពាក្យដែររឺទេ? បើសិនជាអាច សូមជួយប្រាប់ពីភាសាដែលអាចទទួលយកបាន។ យោងតាមប្រការទី១១ (Rule 11) នៃប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ①ការបកប្រែជាភាសាអង់គ្លេសនៃសំណុំលិខិតស្នើសុំភាសាខ្មែររឺ ភាសាបរទេសត្រូវដាក់ជូនក្នុងរយៈពេលប្រាំមួយ(៦)ខែ ហើយ② ការដាក់ពាក្យជាភាសាបរទេសត្រូវបកប្រែជាភាសាខ្មែរហើយដាក់ជូនក្នុងរយៈពេលប្រាំមួយ(៦) ខែ។ ថាតើសំណុំលិខិតស្នើសុំជាផ្លូវការ ត្រូវចាត់ទុកថាលិខិតដែលដាក់មុនរឺ? រឺមួយក៏លិខិតបកប្រែជាភាសាខ្មែរដែលដាក់តាមក្រោយ? តើការកែប្រែលើការបកប្រែខុសជាភាសាខ្មែរអាចធ្វើបានក្នុងអំឡុងពេលដាក់ពាក្យរឺក្រោយបាន ចុះបញ្ជីដែររឺទេ? ក្នុងករណីមានរឿងបណ្តឹងតាមក្រោយ ថាតើអាចពិចារណាយកលើ "លិខិតវាំលំអិតភាសាខ្មែរដែលក្រោយពេលកែប្រែលើការបកប្រែ ខុស"ដែររឺទេ?

7.

ចំពោះរូបមន្តកត់ត្រាពីព្រំប្រទល់នៃស្នើសុំប្រការនីយបត្រតក្កកម្ម ថាតើអាចកត់ត្រានូវJepson Claim, Markush claims, *Means* Plus *Function claims*បានទេ? *ម្យ៉ាងទៀតតើមានកំណត់ក្នុងការបកស្រាយពីសិទ្ធិដែររឺទេ?* *លើសពីនេះទៅទៀត ថាតើអាចយករូបមន្ត* multiple dependent លក្ខណះពហុបានទេ?

※本文の複製、転載、改変、再配布を禁止します。

8.

ប្រសិនបើមានកំណត់លើរូបមន្តនៃ*claims សូមជួយណែនាំ។*

9.

នៅក្នុងលិខិតលំអិត មានតំរូវជាកាតព្វកិច្ចបើកចំហរបច្ចេកទេសមុនដែររឺទេ?

## (trade mark)

10.

ចំពោះការកំណត់ប្រភេទទំនិញ រឺសេវាកម្មដែលមានបំណងការពារនោះ ថាតើអាចកត់ត្រាសរុបបានរឺអត់? ដើម្បីចុះបញ្ជីត្រូវកត់ត្រាលំអិតកំរិតណា?

11.

ថាតើម៉ាកជាអក្សរដែលបានពីភាសាក្រៅពីភាសាខ្មែរ អាចចុះបញ្ជីបានដែររឺទេ? ថាតើម៉ាកដែលប្រើប្រាស់តួអក្សរជប៉ុនKanji, Katakana, Hifagana អាចចុះបញ្ជីបានដែររឺទេ?

12.

ចំពោះម៉ាកដែលល្បីនៅបរទេសតែមិនល្បីនៅប្រទេសកម្ពុជា

① ក្នុងករណីមានដាក់ពាក្យចុះបញ្ជីម៉ាក

※本文の複製、転載、改変、再配布を禁止します。

ប្រសិនបើអ្នកដាក់ពាក្យនោះក្រៅពីម្ចាស់ម៉ាកដែលល្បីនៅបរទេស

ក៏អាចចុះបញ្ជីម៉ាកបានដែររឺទេ?

② ក្នុងករណីអ្នកដែលក្រៅពីម្ចាស់ម៉ាកនៃម៉ាកដែលល្បីនៅបរទេស

កំពុងប្រើប្រាស់ម៉ាកនោះនៅប្រទេសកម្ពុជា ថាតើអាចបង្ក្រាបការប្រើប្រាស់នោះបានរឺអត់?

ក្នុងករណីចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជានោះជាករណីទុច្ចរិត

ថាតើវិនិច្ឆ័យប្រែប្រួលដែររឺទេ?

③ ក្នុងករណីអ្នកដែលក្រៅពីម្ចាស់ម៉ាកនៃម៉ាកដែលល្បីនៅបរទេស

ជាម្ចាស់ម៉ាកនៃម៉ាកនោះនៅប្រទេសកម្ពុជា ថាតើអាចបង្ក្រាបការប្រើប្រាស់នោះបានរឺអត់?

ម្យ៉ាងទៀតអាចលប់ចោលនូវការចុះបញ្ជីម៉ាកនោះបានដែររឺទេ?

ក្នុងករណីចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជានោះជាករណីទុច្ចរិត

ថាតើវិនិច្ឆ័យប្រែប្រួលដែររឺទេ?

13.

យោងតាមមាត្រា១៨នៃអនុក្រឹត

មានចែងពីការបដិសេធន៍មិនព្រមចុះបញ្ជីរបស់មន្ត្រីកាន់កាប់បញ្ជី

អាចប្ដឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ា រឺទៅតុលាការមានសមត្ថកិច្ច

តើក្រុមប្រឹកស្សានោះជាអង្គភាពបែបណា?

ម្យ៉ាងទៀតការបណ្ដឹងតវ៉ាទៅលើអង្គភាពទាំងពីរនោះមានលក្ខណះខុសគ្នាដែររឺទេ?

※本文の複製、転載、改変、再配布を禁止します。

14.

នៅពេលដាក់ពាក្យសុំចុះបញ្ជី
តើចាំបាច់ប្រើប្រាស់ម៉ាកដែលដាក់ពាក្យនោះនៅប្រទេសកម្ពុជាដែររឺទេ?

15.

ចំពោះសេចក្តីប្រកាសដែលចែងនៅក្នុងមាត្រា២១អនុក្រឹត（ Article 21 ）
ក្នុងករណីដាក់សេចក្តីប្រកាសបន្ទាប់ពីខួបលើកទី៥រួចហើយ ចាំបាច់ដាក់ឯកសារដើមទេ
គឺមិនបានជាឯកសារចម្លងទេ?

16.

ក្រោយបាន៥ឆ្នាំបន្ទាប់ពីចុះបញ្ជី និងក្រោយបាន៥ឆ្នាំបន្ទាប់ពីការបន្តម៉ាក
ហើយក្នុងករណីដាក់សេចក្តីប្រកាសអំពីការមិនប្រើប្រាស់នោះ
ថាតើអាចមានករណីលុបចោលនូវការចុះបញ្ជីដែររឺទេ?

17.

គេកំណត់ថាក្នុងពេលដាក់ពាក្យសុំចុះបញ្ជីរឺសុំបន្ត ត្រូវការដាក់គំរូនៃម៉ាកចំនួន១៥
ថាតើត្រូវដាក់អ្វីខ្លះ?

18.

យោងតាមមាត្រា៤(ង)នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម

※本文の複製、転載、改変、再配布を禁止します。

និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានចែងថា ”ម៉ាកដែលដូចគ្នារឺប្រហាក់ប្រហែលដែលនាំអោយច្រឡំគ្នា នឹងម៉ាករឺពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា រឺបង្កើតពីការបកប្រែនៃម៉ាករឺពាណិជ្ជនាមដេលល្បីនោះ សំរាប់ទំនិញរឺសេវាដូចគ្នា រឺប្រហាក់ប្រហែលគ្នា នៃសហគ្រាសមួយទៀត” ត្រូវបដិសេធ ថាតើជាក់ស្តែងព្រំដែននៃការពារម៉ាកនោះមានអនុភាពទៅលើទំនិញស្រដៀងគ្នាដែររឺទេ? ព្រំដែននោះគឺកំរិតប៉ុណ្ណា?

## II. ការដាក់សំណុំលិខិតការពិនិត្យនៅបរទេស

**19.**

យោងតាមមាត្រា៣០និង៣១នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីទាមទារត្រូវដាក់កាល បរិច្ឆេទដាក់ពាក្យនិងលេខរៀងដាប់ពាក្យនៃសំណុំលិខិតស្នើសុំនៅបរទេល របស់តក្កកម្មដូចគ្នា និងឯកសារពាក់ព័ន្ធក្នុងនីតិវិធីពិនិត្យនោះ(សកម្មភាពនៃការិយាល័យ, របាយការណ៍ស្រាវជ្រាវ, ឯកសារចំលងនៃប្រការនីយកម្មតក្កកម្ម និងឯកសារចំលងនៃពិនិត្យបដិសេធន៍) ថាតើតាមជាក់ស្តែងគេទាមទារកំរិតប៉ណ្ណា? តើអាចដាក់តែឯកសារណាមួយក្នុងចំណោម

①របាយការស្រាវជ្រាវអន្តរជាតិ ②របាយការណ៍ស្រាវជ្រាវនៃប្រទេសកំណត់ ③ការវិនិច្ឆ័យនៃប្រទេសកំណត់ ④

※本文の複製、転載、改変、再配布を禁止します。

ឧទាហរណ៍នៃប្រទេសកំណត់រឹសកម្មភាពការិយាល័យបានដែររឺទេ?

## III. អំពីការបើកចំហរ

**20.**

ចំពោះព័ត៌មានស្តីពីការដាក់ពាក្យមុនចុះបញ្ជី ត្រូវបើកចំហរកំរិតប៉ណ្ណា? ក្នុងករណីមានការបើកចំហរ ថាតើតាមរយៈក្រដាសស្នាមមែនទេ? ថាតើព្រឹត្តបត្រផ្លូវការស្តីពីការចុះបញ្ជីប្រការ នីយបត្រតក្កកម្ម ត្រូវអនុវត្តយ៉ាងដូចម្តេច? សូមជួយណែនាំពីនីតិវិធីដកស្រង់និងពិនិត្យព័ត៌មានផ្លូវការ ដែលចែងនៅក្នុងមាត្រា១១៨នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្មផង។

## IV. ការពិនិត្យជាក់លាក់ Substantive examination:

### នីតិវិធីនៃការពិនិត្យ

**21.**

ថាតើត្រូវការធ្វើ នីតិវិធីស្នើសុំពិនិត្យដែររឺទេ? បើមិនចាំបាច់ ថាតើមានករណីធ្វើការបញ្ជាក់ពីឆន្ទះពីការបន្តវិនិច្ឆ័យរបស់អ្នកដាក់ពាក្យដែររឺទេ?

**22.**

តើនីតិវិធីនៃការវិនិច្ឆ័យត្រូវអនុវត្តយ៉ាងដូចម្តេច? ថាតើអនុវត្តពិនិត្យជាក់លាក់ដែររឺទេ?

※本文の複製、転載、改変、再配布を禁止します。

ក្នុងករណីពិចារណាយកពីវិនិច្ឆ័យនៅបរទេស ថាតើយករបស់ប្រទេសណា? រឺមួយក៏ផ្ទេរអោយវិនិច្ឆ័យនៅប្រទេសណាខ្លះ?

**23.**

នៅក្នុងមាត្រា៦៩នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មានចែងថាម៉ូដែលមានអត្ថប្រយោជន៍គឺជា ”តក្កកម្មណាមួយដែលថ្មីនិងអាចយកទៅអនុវត្តបាន ក្នុងវិស័យឧស្សាហកម្ម និងដែលអាចជាផលិតផលឬដំណើរការផលិតកម្ម” ថាតើវិធីផលិតនៃផលិតផលក៏ជាគោលដៅវាដែររឺទេ?

**24.**

សូមជួយបង្ហាញពីព្រំប្រទល់នៃភាពស្រដៀងគ្នានៃគំនូរឧស្សាហកម្ម ដែលអាចប្រើសិទ្ធិបាននោះ។

យោងតាមមាត្រា៩០នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថបនរ យោជន៍និងគំនូរឧស្សាហកម្ម ថាតើព្រំប្រទល់នៃសិទ្ធិនោះត្រូវមានអនុភាពដល់ ”គំនូរឧស្សាហកម្មដែលស្រដៀងក្នុងព្រំដែន នៃអាចកែប្រែយ៉ាងសេរី”ដែររឺទេ?

**25.**

សូមបង្ហាញនីតិវិធីពិនិត្យនូវគំនូរឧស្សាហកម្ម។ ប្រៀបធៀបនឹងប្រការនីយកម្មតក្កកម្ម

※本文の複製、転載、改変、再配布を禁止します。

ថាតើមានភាពខុសគ្នាដូចជារយៈពេលចំណាយរហូតដល់ចុះបញ្ជីខ្លីជាងជាដើមដែររឺទេ?

## V. ការពិនិត្យជាក់លាក់ Substantive examination : អំពីភាពថ្មីភាពថ្មីនិងមានជំហានរកឃើញថ្មី

(តទៅនេះសូមជួយបង្ហាញពីការអនុវត្តន៍នៅថ្ងៃមុខទៀត ដែលទាក់ទងនឹងការពិនិត្យជាក់លាក់ដែលត្រូវចែងនៅក្នុងច្បាប់និងប្រកាស)

**26.**

យោងតាមមាត្រា១៨នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម(លក្ខខណ្ឌកំណត់ត្រា)មានចែងថា ”សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្ម ដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។” ថាតើប្រសិនបើមិនបានកត់ត្រាពីកម្រិតជំនាញនោះ អាចមានលុបចោលនូវតក្កកម្មដែររឺអត់?

**27.**

ថាតើការដាក់ពាក្យមុន ដែលមិនបើកចំហរនៅត្រឹមកាលបរិច្ឆេទអាទិភាពនោះមិនមានបច្ចេកទេសឈានមុខមែនទេ? ពោលគឺប្រសិនបើមិនមែនជាការរកឃើញតក្កកម្មមួយដូចគ្នានៅក្នុងមាត្រា១២នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្មនោះ ការដាក់ពាក្យតាមក្រោយត្រូវចុះបញ្ជីដែររឺទេ?

※本文の複製、転載、改変、再配布を禁止します。

**28.**

យោងតាមមាត្រា១២នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម តើប្រការនីយកម្មតក្កកម្មជាន់គ្នាត្រូវបដិសេធន៍មែនទេ? រឺមួយក៏ ឧទាហរណ៍ក្នុងករណីអ្នកដាក់ពាក្យជាមនុស្សតែម្នាក់ តើការដាក់ពាក្យក្រោយនៃតក្កកម្មដូចគ្នានោះត្រូវចុះបញ្ជីដែររឺទេ?

**29.**

ក្នុងករណីមានដាក់ពាក្យមិនបើកចំហរនៅត្រឹមកាលបរិច្ឆេទអាទិភាពក៏ដោយ ប្រសិនបើវាមិនមែនតក្កកម្មដូចគ្នាទេនោះ ថាតើគេផ្តល់ប្រការនីយកម្មតក្កកម្មដែររឺទេ? តើមានភាពខុសគ្នាដោយសារអ្នកដាក់ពាក្យជាមនុស្សតែមួយរឺអត់?

**30.**

ក្នុងករណីទទួល ថាតើលក្ខខណ្ឌលើកលែង(grace period)នៃការបាត់បង់ការរកឃើញពីមុននៅក្នុងមាត្រា៦នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម តើត្រូវទាមទារពីការកត់ត្រានៅក្នុងសំណុំឯកសារស្នើសុំ រឺដាក់ឯកសារបញ្ជាក់ដែររឺទេ? ប្រសិនបើមានការទាមទារនោះ ថាតើត្រូវការបញ្ជាក់លក្ខណៈយ៉ាងដូចម្តេច? ម្យ៉ាងទៀតក្នុងករណីតក្កករនិងអ្នកប្រកាសមានផ្សេងពីគ្នា តើគេទទួលស្គាល់ពី grace

※本文の複製、転載、改変、再配布を禁止します。

periodដែររឺទេ?

**31.**

ចំពោះវិធីព្យាបាល មិនត្រូវចុះបញ្ជីប្រការនីយកម្មតក្កកម្មទេ ចុះការប្រើប្រាស់ឱសថទី១ ការប្រើប្រាស់ឱសថទី២ អាចយកចុះបញ្ជីបានរឺទេ? បើសិនជាបាន ត្រូវគេទទួលស្គាល់តាមរូបភាពបែបណា?

**32.**

តើប្រការនីយបត្រតក្កកម្មទៅលើអំបិល ដែលជាសារធាតុផ្សំដែលត្រូវសាធារណជនដឹង រឺទ្រង់ទ្រាយនៃកែវcrystal form អាចចុះបញ្ជីបានរឺអត់?

**33.**

“មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម”

នៅក្នុងមាត្រា២៤និង២៥នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម គឺសំដៅទៅលើកាលបរិច្ឆេទពិនិត្យសំរាប់ចុះបញ្ជី រឺមួយក៏កាលបរិច្ឆេទចុះបញ្ជីមួយណា? ការដាក់ពាក្យសំណុំលិខិតស្នើសុំបំបែក អាចដាក់ក្រោយបានពិនិត្យចុះបញ្ជី រឺពិនិត្យបដិសេធន៍បានដែររឺទេ? យោងតាមមាត្រា២៣នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម តើកំណត់កាលបរិច្ឆេទដាក់ពាក្យបំបែកក្នុងករណីគេវិនិច្ឆ័យថាគ្មានភាពតែមួយគត់នោះ

※本文の複製、転載、改変、再配布を禁止します。

គេកំណត់៥ខែ ចុះក្រោយពេល៥ខែ

ទោះបីជាមុនពិនិត្យក៏ដោយយើងមិនអាចដាក់ពាក្យបំបែកបានរឺអត់?

34.

យោងតាមមាត្រា២៧នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម

បានន័យថាអាចអះអាងពីសិទ្ធិអាទិភាពទៅតាមដាក់ពាក្យក្នុងស្រុកកម្ពុជាមែនទេ?

35.

ចំពោះខ្លឹមសារនៃមាត្រា៣២នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម

នឹងមានសុពលភាពក្រោយបានចូលPCTមែនទេ?

36.

ការពន្យាពេលនៃរយៈពេលនីតិវិធី

ដែលចែងនៅមាត្រា១២១នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រ

យោជន៍និងគំនូរឧស្សាហកម្ម ត្រូវចាត់ការក្នុងមូលហេតុយ៉ាងដូចម្ដេច?

ចុះមានប្រកាសណាដែលកំណត់ពីរយៈពេលនីតិវិធីដែររឺទេ?

ម្យ៉ាងទៀតកំណត់ពេលនៃនីតិវិធីនេះនឹងទទួលដំណឹងពីមន្ត្រីកាន់កាប់បញ្ជីមែនទេ?

※本文の複製、転載、改変、再配布を禁止します。

37.

“សវនការ” នៅក្នុងមាត្រា១២២នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម គឺជាការសួរតាមផ្ទាល់មាត់មែនទេ? ឧទាហរណ៍ដូចជាមុននឹងពិនិត្យបដិសេធន៍ មានជូនដំណឹងពីការសួរតាមផ្ទាល់មាត់ដូច្នោះ? កន្លងមកនេះ តើមានករណីពិនិត្យបដិសេធន៍លើប្រការនីយបត្រតក្កកម្មរឺគំនូរឧស្សាហកម្មដែររឺទេ?

38.

នៅប្រទេសកម្ពុជាពុំមានប្រព័ន្ធមជ្ឈករការតវ៉ាលើពិនិត្យបដិសេធន៍ រឺប្រព័ន្ធជម្លួករមោឃះទេហើយត្រូវដាក់ពាក្យបណ្ដឹងនៅតុលាការមែនទេ?

39.

តើមានប្រព័ន្ធផ្ដល់សិទ្ធិអោយរហ័សដែររឺទេ? ក្នុងករណីមានបំណងចង់ចុះបញ្ជីរហ័ស ថាតើមាននីតិវិធីដាក់ពាក្យយ៉ាងដូចម្ដេច? សូមជួយណែនាំទាំងប្រការនីយបត្រតក្កកម្មនិងគំនូរឧស្សាហកម្ម។

## VI. អំពីសិទ្ធិតំណាង

40.

※本文の複製、転載、改変、再配布を禁止します。

យោងតាមមាត្រា១១៦នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម
និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម
ក្នុងករណីបុគ្គលរឺនីតិបុគ្គលដែលស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជាជាអ្នកដាក់ពាក្យ
ត្រូវតែមានតំណាងជាភ្នាក់ងារដែលមានទីលំនៅនិងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រ
កម្ពុជា។ ថាតើភ្នាក់ងារនោះត្រូវមានចុះបញ្ជីដែររឺទេ?
សូមបង្ហាញពីវិធីចុះបញ្ជីក៏ដូចជាកម្មវិធីកម្មសិក្សាវិជ្ជាជីវៈ។

**41.**

តើតំណាងជាភ្នាក់ងារខាងលើមានប៉ុន្មាននាក់?

**42.**

តើតំណាងជាភ្នាក់ងារខាងលើ អាចពាក់ព័ន្ធនឹងការប្រើសិទ្ធិនងរឿងបណ្តឹងដែររឺទេ?

**43.**

តំណាងជាភ្នាក់ងារនៃម៉ាក
និងតំណាងជាភ្នាក់ងាររបស់ប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍
និងគំនូរឧស្សាហកម្ម គឺដូចគ្នាដែររឺទេ? រឺមួយក៏មានគុណសម្បត្តិខុសគ្នា?

# VII. អំពីការរៀបចំច្បាប់បញ្ញត្តិ

**44.**

※本文の複製、転載、改変、再配布を禁止します。

តើមានសេចក្តីព្រៀងច្បាប់រឺប្រការអនុវត្តន៍

ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាណាដែលត្រូវតាក់តែងរឺវិសោធនកម្មក្រោយឆ្នាំ២០០៣ដែររឺទេ?

បើមានសូមជួយបង្ហាញសេចក្តីសង្ខេបនៃខ្លឹមសារនោះ។

ឧទាហរណ៍”សេចក្តីប្រកាសស្តីពីនីតិវិធីនៃការផ្តល់ប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍(ថ្ងៃទី២៨ខែកក្កដាឆ្នាំ២០០៧)” ត្រូវបានអនុវត្តរួចហើយរឺ?

**45.**

ថាតើសេចក្តីប្រកាសរួមសំរាប់ការបង់កំរៃ

ដែលចែងនៅក្នុងមាត្រា១៣០នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្មនោះ បានចេញអោយប្រើប្រាស់ហើយរឺនៅ?

**46.**

សូមណែនាំពីនីតិវិធីសំរាប់កិច្ចសន្យាអាជ្ញាប័ណ្ណ

ដែលចែងនៅក្នុងមាត្រា១១៥នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម និងវិធីប្រើប្រាស់។

ម្យ៉ាងទៀតក្នុងក្រណីការទទួលស្គាល់លើសិទ្ធិអនុវត្តទូទៅ

ក៏ចាំបាច់ចុះបញ្ជីនិងប្រកាសជាសាធារណៈដែររឺទេ?

ថាតើមានបាត់បង់ប្រយោជន៍ណាមួយក្នុងករណីមិនបានចុះបញ្ជីនៃកិច្ចសន្យាអាជ្ញាប័ណ្ណដែររឺអត់?

※本文の複製、転載、改変、再配布を禁止します。

47.

ចំពោះ IPR Enforcement ថាតើ ”ច្បាប់ផ្សេងទៀតជាធរមាន” ដែលចែងនៅក្នុងមាត្រា១២៦នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម គឺសំដៅទៅលើអ្វី? សូមណែនាំពីច្បាប់ដែលកំណត់ពីទោសព្រហ្មទណ្ឌនិងសង់សំណាង់នៃការខូចខាតផង។

48.

ក្នុងការពិនិត្យរឹដកស្រង់នូវចុះបញ្ជី ដែលចែងនៅក្នុងមាត្រា១១៨នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ថាតើ ”លក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ញាទាំងឡាយ” នោះសំដៅទៅលើអ្វីខ្លះ?

49.

ចំពោះកំណត់ស្តីអំពីសំណុំលិខិតស្នើសុំអន្តរជាតិ នៅក្នុងជំពូកទី៤(ពីមាត្រា៧៧ដល់មាត្រា៨៦)នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្មនោះ សព្វថ្ងៃដែលមិនទាន់ចុះចូលPCTនេះ មិនទាន់ត្រូវចេញអោយប្រើប្រាស់ឡើយមែនទេ?

## 【3】សំនួរពាក់ព័ន្ធនឹងការប្រើប្រាស់មុន

※本文の複製、転載、改変、再配布を禁止します。

# I. អំពីច្បាប់រឺបទបញ្ញត្តិពាក់ព័ន្ធ

## 50.

នៅក្នុងមាត្រា៤៤នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មានចែងអំពីសិទ្ធិប្រើប្រាស់មុន។ ក្រៅពីច្បាប់នេះថាតើមានអនុក្រឹត រឺបទបញ្ញត្តិណាដែលចែងពីនីតិវិធីបញ្ជាក់ការប្រើប្រាស់មុនដែររឺទេ? បើមានសូមបង្ហាញពីខ្លឹមសាររឺការបកប្រែភាសាអង់គ្លេស។

# II. អំពីសកម្មភាពអនុវត្ត

## 51.

យើងបានយល់ថា សកម្មភាពអនុវត្តដែលទទួលស្គាល់ពីសិទ្ធិប្រើប្រាស់មុន គឺជាសកម្មភាពអនុវត្តរបស់អ្នកប្រើប្រាស់សុចរិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ រឺមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ។ ចុះថាតើសកម្មភាពអនុវត្តនៅក្រៅប្រទេស ក៏ត្រូវចាត់ទុកថាជាសកម្មភាពអនុវត្តដែររឺទេ? រឺមួយក៏មានតែសកម្មភាពនៅក្នុងស្រុកខ្មែរតែប៉ុណ្ណោះរឺ?

## 52.

ក្នុងករណីគេទទួលស្គាល់ពីសិទ្ធិការប្រើប្រាសមុននៅប្រទេសកម្ពុជា

※本文の複製、転載、改変、再配布を禁止します。

ចំពោះសកម្មភាពអនុវត្តនៅក្រៅប្រទេសនោះ សូមបង្ហាញពីលិខិតស្នាមដែលចាំបាច់ក្នុងការអះអាងពីសិទ្ធិការប្រើប្រាស់មុននោះ និងនីតិវិធីដែលប្រើលិខិតស្នាមនោះយ៉ាងជាក់លាក់ផង។

## 53.

នៅក្នុងមាត្រា៤២នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម គេកំណត់ថាការនាំចូលជាសកម្មភាពសំរាប់អនុវត្តប្រការ នីយបត្រតក្កកម្ម។ ចុះក្នុងការប្រើប្រាស់មុន ថាតើការនាំចូលត្រូវទទួលស្គាល់ថាជាសកម្មភាពអនុវត្តដែររឺទេ? រីឯនាំចេញត្រូវចាត់ទុកដែររឺទេ?

# III. អំពីវិធីធានាបញ្ជាក់ការប្រើប្រាស់មុន

## 54.

នៅប្រទេសជប៉ុន មានវិធីកំណត់កាលបរិច្ឆេទនៅមន្ទីរសារការី។ វាជាការបញ្ជាក់ពីវត្តមាននៃលិខិតស្នាមនៅកាលបរិច្ឆេទចាត់ការនោះ ដែលត្រូវចាត់ទុកថាមានអនុភាពក្នុងនាមជា ភស្តុតាងការប្រើប្រាស់មុន។ ចុះប្រទេសកម្ពុជាវិញ តើមានវិធីកំណត់កាលបរិច្ឆេទពីវត្តមានលិខិតស្នាមដូចខាងលើដែររឺទេ? នៅក្នុងក្រមរដ្ឋប្បវេណីជាដើម តើមានមាត្រាណាដែលពាក់ព័ន្ធនោះដែររឺទេ? គេអាចទទួលស្គាល់ថាជាភស្តុតាងដែលមានអនុភាពសំរាប់បញ្ជាក់ពីការប្រើប្រាស់មុនដូចជប៉ុន ដែររឺអត់?

※本文の複製、転載、改変、再配布を禁止します。

**55.**

នៅប្រទេសជប៉ុន នៅក្នុងវិស័យឯកជនគេអនុវត្តការវាយត្រាពេលTime Stamp ដែលកត់ត្រាថ្ងៃនិងម៉ោងនៅក្នុងលិខិតស្នាមអេឡិចត្រូនិក ។ ចុះនៅប្រទេសកម្ពុជាវិញគេចាត់ទុកថាលិខិតស្នាមដែលមានត្រាពេលនោះ ជាលិខិតដែលវត្តមាននៅពេលវេលានោះដែររឺទេ?

56.

ប្រសិនបើនៅប្រទេសកម្ពុជាមានវិធីកំណត់ពេលវេលាក្រៅពីត្រាពេលនោះ សូមជួយបង្ហាញ។

57.

តើមានវិធីការពារតាមប្រព័ន្ធអេឡិចត្រូនិកទៅលើភស្តុតាងការប្រើប្រាស់មុនដែររឺទេ?

## IV. ផ្សេងៗ

**58.**

ក្នុងសិទ្ធិប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ប្រសិនបើមានករណីវិវាទចំពោះសិទ្ធិការប្រើប្រាស់មុននោះសូមបង្ហាញ។ ជាពិសេសប្រសិនបើមានករណីវិវាទដែលសហគ្រាសបរទេសជាភាគីនោះសូមអោយដឹង។

59.

※本文の複製、転載、改変、再配布を禁止します。

នៅប្រទេសកម្ពុជាមានវិធីណាដែលការពារសម្ងាត់ប្រតិបត្តិអាជីវកម្មដែររឺទេ?

## 【4】អំពីប្រការនីយបត្រតក្កកម្មលើផលិតផលឱសថ

### I. អំពីការពន្យាពេលប្រការនីយបត្រតក្កកម្មនិងការទំនាក់ទំនងប្រការនីយបត្រតក្កកម្មPatent Linkage

60.

ចំពោះផលិតផលឱសថ មិនត្រូវការពារដោយប្រកាសនីយបត្រតក្កកម្មនាពេលសព្វថ្ងៃ ដោយយោងតាមមាត្រា១៣៦នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ចុះប្រការនីយបត្រតក្កកម្មវត្ថុធាតុលើធាតុផ្សំ រឺប្រការនីយបត្រតក្កកម្មវិធីផលិត ក៏គ្មានអនុភាពទៅលើផលិតផលឱសថដែរ? ម្យ៉ាងទៀតយើងអាចយល់ឃើញថា ចាប់ពីថ្ងៃទី១ខែមករាឆ្នាំ២០១៦ទៅ ប្រការនេះត្រូវលប់ចោល ហើយអនុភាពនៃប្រការនីយបត្រតក្កកម្មផ្តល់លើឱសថវិញមែនទេ? អាចមានការពន្យាកាលបរិច្ឆេទខាងលើដែររឺអត់?

**61.**

អំឡុងពេលដែលចំណាយចាប់ពីពិសោធន៍ជាក់លាក់រហូតដល់ដាក់ពាក្យ ដែលយោងតាមការទាមទារពីសំណាក់អង្គភាពចុះបញ្ជីឱសថនោះ

※本文の複製、転載、改変、再配布を禁止します。

ថាតើមានប្រព័ន្ធពន្យាកំឡុងពេលបន្តប្រការនីយបត្រតក្កកម្មឱសថដែររឺទេ? រឺក៏អាចបង្កើតប្រព័ន្ធនាពេលអនាគតដែររឺទេ?

62.

អង្គភាពចុះបញ្ជីឱសថ ធ្វើការពិនិត្យដោយបញ្ជាក់ពីមាន រឺអត់មាន នូវប្រការនីយបត្រតក្កកម្មដែររឺអត់?

63.

ក្នុងការពិនិត្យដោយអង្គភាពចុះបញ្ជីឱសថ

ថាតើការដាក់ពាក្យនូវផលិតផលឱសថGeneric drug មិនបាច់ធ្វើពិសោធន៍ជាក់លាក់ពេញលេញ ហើយគ្រាន់តែបង្ហាញពី Bioequivalence ទៅទើបគេនឹងផ្តល់ការអនុញ្ញាតមែនទេ?

64.

ចំពោះសំនួរខាងលើ ប្រសិនបើគេផ្តល់ការអនុញ្ញាត ថាតើមានប្រព័ន្ធ ”ការពារទិន្នន័យ” ចំពោះការដាក់ពាក្យសុំផលិតផលឱសថបង្កើតថ្មីinnovator drugដែររឺទេ?

## 【5】 ប្រការផ្សេងៗ

65.

※本文の複製、転載、改変、再配布を禁止します。

ក្នុងបទពិសោធន៍របស់អង្គភាពរបស់លោក លោកស្រី ប្រសិនបើមានសហគ្រាសបរទេសតែងតែខុស រឺយល់ច្រឡំទៅលើកម្មសិទ្ធិបញ្ញា(ដាក់ពាក្យ ចាត់ការឆ្លើយតប បណ្ដឹងនៅតុលាការ)សូមណែនាំអោយដឹងផង។

66.

ចំពោះការិយាល័យប្រការនីយបត្រតក្កកម្ម រឺក្រុមហ៊ុនស្រាវជ្រាវជាដើម គេអនុវត្តការស្រាវជ្រាវបច្ចេកទេសប្រើប្រាស់មុន រឺស្រាវជ្រាវឯកសារមោឃះយ៉ាងដូចម្ដេច?

※本文の複製、転載、改変、再配布を禁止します。

៦៣(63)

អំពីសិទ្ធិអនុវត្តដោយបញ្ហា

មានចែងមាត្រា៥៦ដល់មាត្រា៦៣នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម

ថាតើមាននីតិវិធីដាក់ពាក្យពីសំណាក់អ្នកមានបំណងអនុវត្តទេ?

រឺមួយក៏វាត្រូវកំណត់ដោយរដ្ឋាភិបាល?

៦៥(65)

នៅក្នុងមាត្រា៤៤នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម មានចែងអំពីសិទ្ធិប្រើប្រាស់មុន។ សូមបង្ហាញពីព្រំដែនដែលទទួលស្គាល់ពីសិទ្ធិប្រើប្រាស់មុន និងនីតិវិធីចាំបាច់សំរាប់អះអាំងពីសិទ្ធិប្រើប្រាស់មុន។

៦៧(67)

យល់ថា តក្កកម្មដែលកើតនៅព្រះរាជាណាចក្រកម្ពុជា មិនចាំបាច់ដាក់ពាក្យសុំនៅប្រទេសកម្ពុជាទេមែនទេ?